## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ
# ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ(Zoom)

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និង អង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២៨ និងតាមប្រព័ន្ធអនឡាយចំនួន៣៨រូប សរុបចំនួន៦៦រូប។

**៤. របៀបវារៈ៖**

៤.១- មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២- បទបង្ហាញស្តីពីវឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បង្ហាញដោយ **ឯកឧត្តមបណ្ឌិត ស៊ឹម សុផៃ** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣- មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. លទ្ធផល ៖**

**៥.១** ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី១០ ឆ្នាំ២០២៤ ក្រោមប្រធានបទ "វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ឆ្នាំ២០២៤" របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាបន្ត **ឯកឧត្តមបណ្ឌិត** ក៏បានបញ្ជាក់រំលឹកឡើងវិញពីការប្រឹងប្រែងចូលរួមក្នុងឆ្លើយតបនឹងមេរោគអេដស៍ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ចាប់តាំងពីការរកឃើញមេរោគអេដស៍ជាលើកដំបូងនៅប្រទេសកម្ពុជានាឆ្នាំ១៩៩១ ទាំងលើផ្នែកបង្ការ ការព្យាបាល និងគាំទ្រ ដែលរហូតមកដល់ឆ្នាំ២០២៣នេះ កម្ពុជាសម្រេចបាន ៨៩-៩៨-៩៨។ ការសម្រេចបាននូវលទ្ធផលនេះ គឺដោយសារមានការយកចិត្តទុកដាក់ពីអតីតប្រមុខរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានអំពាវនាវជាចលនាជាតិតែមួយក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងគិតគូប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ក្នុងការសម្រេចឱ្យបាននូវគោលដៅជាតិ ៩៥-៩៥-៩៥ ទាំងបីក្នុងឆ្នាំ ២០២៥ ព្រមទាំងមានចូលរួមអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកជាតិ អន្តរជាតិ និងសង្គមស៊ីវិល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងឈានទៅសម្រេចបានគោលនយោបាយជាតិទាំងបី៖

១- កាត់បន្ថយការចម្លងថ្មីតិចជាង ១នាក់ ឬប្រមាណជា ២០០នាក់ក្នុងមួយឆ្នាំ

២- កាត់បន្ថយការស្លាប់ដោយសារមេរោគអេដស៍ ឱ្យនៅក្រោម ២០០នាក់ក្នុងមួយឆ្នាំ

៣- លុបបំបាត់ការមាក់ងាយ និងរើសអើង។

ដំណើរការនៃកិច្ចប្រជុំមាន៖

**៥.២ ឯកឧត្តមបណ្ឌិត** បានអនុញ្ញាតជូន**ឯកឧត្តមបណ្ឌិត ស៊ឹម សុផៃ អគ្គលេខាធិការរង និងជាអនុប្រធានក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** ធ្វើបទបង្ហាញដែលផ្តោតលើ៖

១- បច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។

២- សកម្មភាព និងសមិទ្ធផលចម្បងៗ នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២៤។

៣-បញ្ហាប្រឈមនានាក្នុងការឆ្លើយតបនឹងមេរោគអេដស៍។

៥- ទិសដៅអនុវត្តបន្ត។

**ឯកឧត្តមបណ្ឌិត** បានបញ្ជាក់ថា ក្នុងឆ្នាំ២០២៣ កម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧៦ ០០០នាក់ មានអត្រាផ្ទុកមេរោគអេដស៍ចំនួន៥% មានអ្នកឆ្លងថ្មីប្រមាណជា ១ ២០០នាក់ អ្នកឆ្លងថ្មីនៃក្រុមប្រជាជនគន្លឹះ និងអតិថិជនរួមនឹងដៃគូមាន ៨៦% បុរសរួមភេទជាមួយបុរសមាន ៤៦% ស្ត្រីបម្រើសេវាកម្សាន្តសប្បាយមាន ៧%។ ជាលទ្ធផលក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងគោលដៅ៩៥ទី១ បាន៨៩% ចំណែកគោលដៅ៩៥ទី២ និងទី៣បានសម្រេច ៩៨%។

អ្នកផ្ទុកមេរោគអេដស៍ ៦៨ ៨០០នាក់ បានទទួលសេវាថែទាំ និងព្យាបាលជំងឺអេដស៍។ មកដល់ត្រីមាសទី២ ឆ្នាំ២០២៤ មានអ្នកផ្ទុកមេរោគអេដស៍បានទទួលប័ណ្ណមូលនិធិសមធម៌ចំនួន ៣៩ ១៨៧នាក់ គឺស្មើ ៥៧% ក្នុងចំណោមអ្នកជំងឺអេដស៍សកម្មដែលទទួលសេវាថែទាំចំនួន ៦៨ ៨២២ នាក់។

**ឯកឧត្តមបណ្ឌិត** ក៏បានលើកបង្ហាញពីគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ក្នុងចក្ខុវិស័យធានាថា ប្រទេសកម្ពុជាជាប្រទេសមួយដែលគ្មានការគំរាមកំហែងពីមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងធានាថា ប្រជាជនកម្ពុជាមានសុខភាពល្អ និងរស់នៅប្រកបដោយសុខុមាលភាព គ្មានការភ័យខ្លាចដោយសារជំងឺអេដស៍។ ចំណែកផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨ ក្នុងចក្ខុវិស័យ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញគ្មានមេរោគអេដស៍ និងជំងឺអេដស៍ គ្មានការមាក់ងាយ និងរើសអើង។ តាមរយៈផែនការយុទ្ធសាស្ត្រចំនួន៤គឺៈ

១- ផ្តល់ការបង្ការ ព្យាបាល ថែទាំ និងគាំទ្រទូលំទូលាយ និងមានប្រសិទ្ធភាពតាមរយៈការសម្របសម្រួលល្អ និងប្រើប្រាស់វិធីសាស្ត្រជំរុញការចូលរួមជាពហុវិស័យ។

២- ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គម និងបង្កើតបរិយាកាសអំណោយផលដល់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ បានទទួលសេវាអេដស៍ សេវាសុខាភិបាល និងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមប្រកបដោយប្រសិទ្ធភាព។

៣- កសាងសមត្ថភាពស្ថាប័ន សហគមន៍ និងបុគ្គល ដើម្បីពង្រឹងការឆ្លើយតបសហគមន៍ និងកែលម្អការធ្វើសមាហរណកម្មឆ្លើយតបនឹងមេរោគអេដស៍ក្នុងវិស័យសុខាភិបាល និងវិស័យមិនមែនសុខាភិបាល។

៤- ធានាចីរភាពសមិទ្ធផលជាតិនៃការឆ្លើយតបនឹងមេរោគអេដស៍ ដោយការបង្កើនការវិនិយោគជាតិ និងការពង្រឹងប្រព័ន្ធនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈអភិបាលកិច្ច សម្របសម្រួល និងត្រួតពិនិត្យ។

បន្ទាប់មក **ឯកឧត្តមបណ្ឌិត** បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួន ដែលត្រូវមានវិធានការណ៍ដោះស្រាយជាបន្តដូចជា៖

- អត្រាឆ្លងថ្មីនៃមេរោគអេដស៍ និងអត្រាប្រេវ៉ាឡង់ជំងឺកាមរោគ មានកម្រិតខ្ពស់ក្នុងចំណោមក្រុមប្រឈមមុខ ជាពិសេសក្រុមប្រជាជនគន្លឹះជាយុវវ័យ។
- អត្រានៃអ្នកដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនទើបតែសម្រេចបាន ៨៩% ឆ្នាំ២០២៣ធៀបនឹងគោលដៅ (៩៥% ទី១)។
- ការទទួលបានសេវាបង្ការការឆ្លងមេរោគអេដស៍ ជាពិសេសសេវា PrEP និងសេវាធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនគន្លឹះនៅមានកម្រិត (៤៤%)។
- ការលេចឡើងនូវឥរិយាបទប្រឈមថ្មីៗដូចជា ការប្រើប្រាស់បណ្តាញសង្គម (Social Media) ដើម្បីស្វែងរកដៃគូរួមភេទ ក្រុមអ្នកប្រើគ្រឿងញៀននៅពេលរួមភេទ (Chemsex) ដែលមិនបានបង្ការពីការឆ្លងមេរោគអេដស៍។

- វិសមភាពក្នុងការទទួលបានសេវាធ្វើតេស្ត និងព្យាបាលជំងឺអេដស៍សម្រាប់កុមារ ហើយអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូននៅមានកម្រិតខ្ពស់។

ចុងបញ្ចប់នៃបទបង្ហាញ **ឯកឧត្តមបណ្ឌិត** បានលើកឡើងពីការងារត្រូវអនុវត្តបន្ត ដូចខាងក្រោម៖

- បន្តអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨។
- បន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី ៦ ឆ្នាំ២០២៤-២០២៨។
- បន្តផែនការយុទ្ធសាស្ត្រសម្រាប់បង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ក្នុងវិស័យសុខាភិបាលឆ្នាំ២០២១-២០២៥។
- បន្តអនុវត្តលិខិតលេខ ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ អំពីការដាក់វិធានការទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍របស់ទីស្តីការគណៈរដ្ឋមន្ត្រី។
- បន្តរៀបចំនិងធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- បន្តរៀបចំផែនការសកម្មភាព និងថវិកាឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- ជំរុញការផ្សព្វផ្សាយលើកទឹកចិត្តការធ្វើតេស្តរកមេរោគអេដស៍ដល់ប្រជាជនទូទៅ ជាពិសេសប្រជាជនគន្លឹះ ដើម្បីឆ្ពោះទៅសម្រេចគោលដៅ៩៥ ទី១។
- ពង្រឹងការអនុវត្តសកម្មភាពកាត់បន្ថយការបោះបង់សេវារបស់អ្នកជំងឺអេដស៍ តាមរយៈការបង្វិតសេវាទៅជិតសហគមន៍ និងការចូលរួមរបស់សហគមន៍ ក្នុងការផ្តល់សេវា និងតាមរកអ្នកជំងឺខកណាត់ជួប។
- ស្វែងរកកិច្ចសហការជាមួយសេវាឯកជន ក្នុងការផ្តល់សេវាបង្ការ និងព្យាបាលជំងឺអេដស៍។
- បង្កើនការចុះឈ្មោះជូនដល់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រឈមបានទទួលប័ណ្ណមូលនិធិសមធម៌សុខាភិបាល ។

**មតិយោបល់៖**

- លោកតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ចូលថវិកាទៅក្នុងសៀវភៅថវិកាសម្រាប់ឆ្នាំ២០២៥ តាំងពីខែសីហា ឆ្នាំ២០២៤ រួចហើយ ដូចនេះ ស្នើសុំឱ្យរាជធានី ខេត្ត អនុវត្តការងារចាប់ពីដើមឆ្នាំទៅ។ លោកបានស្នើឱ្យមានការបញ្ចូលប្រភពចំណាយរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការឆ្លើយតបនឹងមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ ទៅក្នុងរបាយការណ៍ចំណាយ។
- លោកតំណាង មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានមានចំណាប់អារម្មណ៍លើទិន្នន័យមួយចំនួនដែលមិនទាន់ធ្វើបច្ចុប្បន្នភាព ព្រមទាំងស្នើសុំឱ្យមានការកែសម្រួលឡើងវិញ។

ជាបន្ត **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ បានអនុញ្ញាតឱ្យមានកិច្ចពិភាក្សា និងផ្តល់យោបល់យ៉ាងផុលផុស និងមានសំណូមពរពីតំណាងCNPUD សូមឱ្យមានការផ្សព្វផ្សាយក្នុងសាលា ពេលសាលាមានការជួបជុំជាមួយអាណាព្យាបាល។

ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** បានផ្តល់នូវមតិ និងអនុសាសន៍ដល់កិច្ចប្រជុំដូចខាងក្រោម៖

- ចាប់ផ្តើមផ្សព្វផ្សាយដោយផ្ទាល់ក្នុងកម្រិតមហាវិទ្យាល័យសម្រាប់និស្សិត។
- បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់កម្មវិធីអប់រំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងជំងឺអេដស៍នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍៕

ថ្ងៃពុធ ១៣រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង**
**និងចលនាប្រភពធនធាន**

**វេជ្ជ. ហួត សេរីវង្ស**

អ្នកធ្វើរបាយការណ៍

**ស៊ុំ ផល្លា**

**ប្រធានអង្គប្រជុំ**

**បណ្ឌិត ឈឹម ឃិនដារ៉េត**